# ប្រធានផ្នែកដោះស្រាយបំណុល ( Loan Recovery Unit Manager )

សិទ្ធិអនុម័ត ៖ តាមកម្រិតសិទ្ធិដែលបានផ្ដល់ឲ្យដោយថ្នាក់មានសមត្ថកិច្ច
រចនាសម្ព័ន្ធគ្រប់គ្រង ៖ ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ របស់នាយកនាយកដ្ឋានប្រតិបត្តិការ

## ក. តួនាទី និងភារកិច្ច ( Job Description )

១. សិក្សាស្វែងយល់ឱ្យច្បាស់លាស់ និងទាន់សម័យ នូវរាល់គោលការណ៍ នីតិវិធី សេចក្ដីណែនាំផ្សេងៗ ពាក់ព័ន្ធនឹងកិច្ចការងារជំនាញ ក្នុងរង្វង់តួនាទី ដើម្បីប្រសិទ្ធការអនុវត្តការងារ ។

២. រៀបចំផែនការប្រមូលប្រាក់កំចីយឺតយ៉ាវ ដល់មន្ត្រីដោះស្រាយបំណុល ផែនការជាអាទិភាពចំពោះអតិថិជនដែលខកខានសងប្រាក់យឺតយូរ និងផែនការយុទ្ធសាស្ត្រក្នុងផ្នែកជំនាញ ដើម្បីធ្វើការដោះស្រាយទៅតាមនីតិវិធី របស់គ្រឹះស្ថាន មហានគរ មីក្រូហិរញ្ញវត្ថុ ឱ្យមានប្រសិទ្ធភាព ។

៣. យល់ដឹងពីផែនការយុទ្ធសាស្ត្រការងារ ក្នុងផ្នែកសាមី និងរៀនចំចាត់ចែង បែងចែកការងារការទទួលខុសត្រូវជូននិយោជិត ឱ្យសមស្របទៅតាមទំហំការងារ ។

៤. សិក្សារកមូលហេតុ និងប្រមូលព័ត៌មាន ដែលនាំឲ្យកើតមានបញ្ហាខកខានមិនបានសងប្រាក់ ទាំងមុនពេលជួប និងកំឡុងពេលជួបអតិថិជន ។

៥. ចាត់ចែង តាមដានយ៉ាងទៀងទាត់នៅតាមសាខា នូវបំណុលដែលខកខានមិនបានសងត្រឡប់ដើម្បីចាត់វិធានការដោះស្រាយបានទាន់ពេលវេលា ។ ត្រួតពិនិត្យនូវទំនោរកំណើនហានិភ័យ ទំនោរបំណុលលុបចេញពីបញ្ជី ការប្រមូលបំណុល និងការធ្វើចំណាត់ថ្នាក់បំណុល ។

៦. ដោះស្រាយ ការប្រមូលបំណុល នៅតាមសាខា និងធ្វើចំណាត់ថ្នាក់បំណុល ព្រមទាំងរៀបចំសំណើសុំប្ដឹងអតិថិជនទៅតុលាការ និងចូលរួមដំណើរការរឿងក្ដី ឱ្យបានត្រឹមត្រូវ ។

៧. ចុះជួបជាមួយ អាជ្ញាធរ ដើម្បីសាកសួរពីព័ត៌មានដែលពាក់ព័ន្ធ ជាមួយអតិថិជនយឺតយ៉ាវ ។

៨. កំណត់ពេលវេលាជាក់លាក់មួយ ក្នុងការណាត់ជួបអតិថិជន ដែលមានបញ្ហាយឺតយ៉ាវ ដើម្បីធ្វើការចរចារ និងស្វែងរកដំណោះស្រាយ ។

៩. រៀបចំរបាយការណ៍អតិថិជនយឺតយ៉ាវ ជូននាយកប្រតិបត្តិការជាប្រចាំ និងកំណត់ឲ្យបានច្បាស់លាស់ ទៅលើអតិថិជនដែលមានបញ្ហាធ្ងន់ធ្ងរពិបាកដោះស្រាយ ។

១០. ទទួលខុសត្រូវចំពោះកិច្ចការផ្សេងៗទៀតតាមការចាត់តាំង ឬតាមតម្រូវការរបស់អ្នកគ្រប់គ្រងផ្ទាល់ក្នុងសមត្ថកិច្ចតួនាទី និងរាល់បញ្ហាដែលកើតមានក្នុងតួនាទី ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់ថ្នាក់គ្រប់គ្រងផ្ទាល់ តាមរចនាសម្ព័ន្ធដើម្បីដោះស្រាយ ។

## ខ. លក្ខណសម្បត្តិ ( Job Requirement )

១. កំរិតវប្បធម៌ចប់បរិញ្ញាបត្រ ពាក់ព័ន្ធនិងធនាគារ ទីផ្សារ សេដ្ឋកិច្ច ឬជំនាញពាក់ព័ន្ធផ្សេងទៀត

២. យ៉ាងតិចមានបទពិសោធន៍ ២ឆ្នាំទាក់ទងនិងផ្នែកឥណទាន ដោះស្រាយបំណុល

៣. មានចំណេះដឹងខាងផ្នែកបច្ចេកទេសដូចជា Ms. Word, Excel

៤. មានទំនាក់ទំនងល្អគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ និងបង្កើនភាពទុកចិត្ត

៥. មានភាពស្មោះត្រង់ សុខភាពល្អ មានឆន្ទៈខ្ពស់ចំពោះការងារ មានភាពអត់ធ្មត់ ។

## មន្ត្រីផ្នែកដោះស្រាយបំណុល ( Loan Recovery Officer )

សិទ្ធិអនុម័ត ៖ តាមកម្រិតសិទ្ធិដែលបានផ្តល់ឲ្យដោយថ្នាក់មានសមត្ថកិច្ច
រចនាសម្ព័ន្ធគ្រប់គ្រង ៖ ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ របស់ប្រធានផ្នែកដោះស្រាយបំណុល

### ក. តួនាទី និងភារកិច្ច ( Job Description )

១. សិក្សាស្វែងយល់ឱ្យច្បាស់លាស់ និងទាន់សម័យ នូវរាល់គោលការណ៍ នីតិវិធី សេចក្តីណែនាំ ផ្សេងៗ ពាក់ព័ន្ធនឹងកិច្ចការងារជំនាញ ក្នុងតួនាទី ដើម្បីប្រសិទ្ធការអនុវត្តការងារ ។
២. រៀបចំផែនការប្រមូលប្រាក់កំចីយឺតយ៉ាវ ចំពោះអតិថិជនដែលខកខានសងប្រាក់យឺតយូរ រៀបចំផែនការយុទ្ធសាស្រ្ត ដើម្បីធ្វើការដោះស្រាយទៅតាមនីតិវិធីរបស់គ្រឹះស្ថានមហាឧត្តមីក្រូហិរញ្ញវត្ថុ ឱ្យមានប្រសិទ្ធភាព។
៣. សិក្សារកមូលហេតុ និងប្រមូលព័ត៌មាន ដែលនាំឲ្យកើតមានបញ្ហាខកខានមិនបានសងប្រាក់ ទាំងមុនពេលជួប និងកំឡុងពេលជួបអតិថិជន ។
៤. តាមដានយ៉ាងទៀងទាត់នៅតាមសាខា នូវបំណុលដែលខកខានមិនបានសងត្រឡប់ ដើម្បីចាត់វិធានការដោះស្រាយបានទាន់ពេលវេលា ។ ត្រួតពិនិត្យនូវទំនោរកំណើនហានិភ័យ ទំនោរបំណុលលុបចេញពីបញ្ជី ការប្រមូលបំណុល និងការធ្វើចំណាត់ថ្នាក់បំណុល ។
៥. ដោះស្រាយការប្រមូលបំណុល នៅតាមសាខា និងធ្វើចំណាត់ថ្នាក់បំណុល ព្រមទាំងរៀបចំសំណើសុំប្តឹងអតិថិជនទៅតុលាការ និងចូលរួមដំណើរការរឿងក្តី ឱ្យបានត្រឹមត្រូវ ។
៦. ចុះជួបជាមួយ អាជ្ញាធរ ដើម្បីសាកសួរពីព័ត៌មានដែលពាក់ព័ន្ធ ជាមួយអតិថិជនយឺតយ៉ាវ ។
៧. កំណត់ពេលវេលាជាក់លាក់មួយ ក្នុងការណាត់ជួបអតិថិជន ដែលមានបញ្ហាយឺតយ៉ាវ ដើម្បីធ្វើការចរចារ និងស្វែងរកដំណោះស្រាយ ។
៨. រៀបចំរបាយការណ៍អតិថិជនយឺតយ៉ាវ ជូននាយកប្រតិបត្តិការជាប្រចាំ និងកំណត់ឲ្យបានច្បាស់លាស់ទៅលើអតិថិជនដែលមានបញ្ហាធ្ងន់ធ្ងរពិបាកដោះស្រាយ ។
៩. ការងារទទួលខុសត្រូវចំពោះកិច្ចការផ្សេងៗទៀតតាមការចាត់តាំង ឬតាមតម្រូវការរបស់អ្នកគ្រប់គ្រងផ្ទាល់ក្នុងសមត្ថកិច្ចតួនាទី និងរាល់បញ្ហាដែលកើតមានក្នុងតួនាទី ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់ថ្នាក់គ្រប់គ្រងផ្ទាល់ តាមរចនាសម្ព័ន្ធដើម្បីដោះស្រាយ ។

### គ. លក្ខណសម្បត្តិ ( Job Requirement )

១. កំរិតវប្បធម៌ចាប់ពីនិស្សិតឆ្នាំទី៣ឡើងទៅ ពាក់ព័ន្ធនិងធនាគារ ទីផ្សារ សេដ្ឋកិច្ច ឬជំនាញពាក់ព័ន្ធផ្សេងទៀត
២. យ៉ាងតិចមានបទពិសោធន៍ ២ឆ្នាំទាក់ទងនិងផ្នែកឥណទាន ដោះស្រាយបំណុល
៣. មានចំណេះដឹងខាងផ្នែកបច្ចេកទេសដូចជា Ms. Word, Excel
៤. មានទំនាក់ទំនងល្អគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ និងបង្កើនភាពទុកចិត្ត
៥. មានភាពស្មោះត្រង់ សុខភាពល្អ មានឆន្ទៈខ្ពស់ចំពោះការងារ មានភាពអត់ធ្មត់ ។